ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៧ និងទិសដៅការងារឆ្នាំ២០០៨
## របស់ធនាគារជាតិនៃកម្ពុជា

នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី ៦_៧ ខែមីនា ឆ្នាំ២០០៨

៚៚៚✻៚៚៚

សូមគោរព :

- លោកជំទាវ ទេសាភិបាលរង
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក្នុងឱកាសប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៧ និងទិសដៅការងារឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា ។ ជារៀងរាល់ឆ្នាំ យើងតែងតែប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារពីរដងក្នុងមួយឆ្នាំ ក្នុងបំណងដើម្បីអបអរសាទរ និងផ្សព្វផ្សាយពីលទ្ធផលការងារ ដែលធនាគារជាតិនៃកម្ពុជាយើងសំរេចបានកន្លងមកផង និងម្យ៉ាងទៀត ដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើង ទាំងនៅស្នាក់ការកណ្តាល និងនៅខេត្តក្រុងបានជួបប្រាស្រ័យនិងរាប់អានគ្នាកាន់តែជិតស្និទ្ធថែមទៀត ដូចយើងរស់នៅក្រោមដំបូលគ្រួសារតែមួយ ជាមួយគ្នា ។ សន្និបាតរបស់យើងឆ្នាំនេះ បានប្រារព្ធធ្វើឡើងរយៈពេលពីរថ្ងៃមុន ទិវានារីអន្តរជាតិ៨មីនា ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលជាតំណាងនាយកដ្ឋាននានានៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើង នាពេលនេះ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើង ដែលបានរួមចំណែកកសាងសមិទ្ធផលទាំងឡាយជូនធនាគារជាតិនៃកម្ពុជាកន្លងមក *ពោលគឺ* បានកសាងប្រព័ន្ធធនាគារយើងឱ្យមានការរីកចំរើន មានសុវត្ថិភាព មានសុខភាពរឹងមាំ និងទទួលបានការជឿទុកចិត្តបន្ថែមទៀតពីសាធារណជនទូទៅ រាជរដ្ឋាភិបាល និងពីសហគមន៍អន្តរជាតិ ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

គោលបំណងសំខាន់នៃការរៀបចំអង្គសន្និបាតរបស់យើងថ្ងៃនេះ គឺដើម្បីផ្សព្វផ្សាយពី :

១- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០៧

២- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆ្នាំ២០០៧

## ១. សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

សេដ្ឋកិច្ចពិភពលោកយើងនាពេលបច្ចុប្បន្ននេះ កំពុងប្រឈមនឹងបញ្ហាធំៗពីរគឺ *ទី១*-វិបត្តិឥណទាននិក្ខេប (Subprime Mortgage Loan Crisis) និង *ទី២*-វិបត្តិនៃការកើនឡើងថ្លៃប្រេង ។ បើតាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា នៅឆ្នាំ២០០៧ សេដ្ឋកិច្ចពិភពលោកមានអត្រាកំណើន ៥,២% ទាបជាងអត្រាកំណើនឆ្នាំមុន ៥,៤% បន្តិច ខណៈដែលសកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសមហាអំណាចឧស្សាហកម្ម បានបង្ហាញឱ្យឃើញពីនិន្នាការថយចុះ ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍន៍វិញ មានល្បឿននៃកំណើនសេដ្ឋកិច្ចកើនឡើងយ៉ាងខ្លាំង ។ កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៧ គ្រោងថានឹងមានកម្រិត ១.៩% ចំណែកឯកំណើនសេដ្ឋកិច្ចនៅតំបន់អឺរ៉ុបមានកម្រិតត្រឹម ២.៥% ។ សេដ្ឋកិច្ចបណ្តាប្រទេសអាស៊ី ត្រូវបានរំពឹងថា មានកំណើនខ្ពស់ ដោយសារសន្ទុះកំណើនដ៏ប្រសើររបស់សេដ្ឋកិច្ចប្រទេសចិន និងឥណ្ឌារក្សាបានអត្រាកំណើនប្រចាំឆ្នាំប្រមាណ ១០% ។

ចំពោះកំណើនសេដ្ឋកិច្ចនៃក្រុមប្រទេសអាស៊ានវិញ បើតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានឱ្យដឹងថា នៅក្នុងឆ្នាំ២០០៧ នឹងកើនឡើងក្នុងកំរិត ៧% ពោលគឺទាបជាងឆ្នាំ២០០៦ ដែលមានកំណើន ៨,៧% ដោយសារផលប៉ះពាល់ពីខាងក្រៅតំបន់ ។ ជាទូទៅ នៅឆ្នាំ២០០៧ ពិភពលោកមានសុទិដ្ឋិនិយមចំពោះវឌ្ឍនភាពសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលអាចរក្សាលំនឹងបានល្អប្រសើរ ។

ចំណែកឯសេដ្ឋកិច្ចកម្ពុជាវិញ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ យើងក៏មានមោទនភាពយ៉ាងខ្លាំងដែរ ដោយអត្រាកំណើនមានស្ថិរភាពល្អប្រសើរលើសពីការរំពឹងទុក នៅឆ្នាំ២០០៥ កំណើនផលិតផលក្នុងស្រុកកើនឡើងដល់ ១៣,៥% នៅ ឆ្នាំ២០០៦ កើនដល់ ១០,៨% ។ បើតាមរបាយការណ៍ផ្លូវការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករដោយប្រុងប្រយ័ត្នថា នៅឆ្នាំ២០០៧ សេដ្ឋកិច្ចកម្ពុជានឹងមានអត្រាកំណើន ៩.៦% និងនៅឆ្នាំ២០០៨ មានកំរិត ៧.៩% ។ ជារួមយើងព្យាករណ៍ថា អត្រាកំណើននេះនឹងមានល្បឿនជាមធ្យមក្នុងកំរិត ៧.៥% រហូតដល់ឆ្នាំ២០១២ ។

កត្តាដែលអាចរក្សាល្បឿននៃកំណើននេះ បណ្តាលមកពីភាពអំណោយផលពី *១*-វិស័យកសិកម្ម និងសំណង់ *២*-វិស័យទេសចរណ៍ *៣*-ការនាំចេញផលិតផលវាយនភណ្ឌ *៤*-ស្ថិរភាពនៃអត្រាប្តូរប្រាក់ និងអតិផរណាទាប ប្រែប្រួលក្នុងកំរិតអាចគ្រប់គ្រងបាន *៥*-ប្រសិទ្ធភាពនៃអន្តរការិយកម្មធនាគារនិងហិរញ្ញវត្ថុ ក្នុងការគៀងគរសញ្ជ័យ និង*ជាពិសេស គឺ* ស្ថិរភាពនយោបាយល្អប្រសើរ ក្នុងខណៈដែលប្រទេសកម្ពុជាយើង កំពុងត្រៀមរៀបចំបោះ

ឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី ៤ នៃរដ្ឋសភា ។ ទាំងនេះគឺជាកត្តាគន្លឹះសំរាប់ពង្រឹងជំនឿទុកចិត្ត និងបង្ហាញពីភាពប្រាកដប្រជានៃការតម្រង់ទិសវិនិយោគដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ។

## ២. លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆ្នាំ២០០៧

ក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ជាលទ្ធផល ក្នុងឆ្នាំ២០០៧ កន្លងមក ធនាគារជាតិនៃកម្ពុជាបានសំរេចសមិទ្ធផលសំខាន់ៗ ដូចតទៅ :

*១).* **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច :** ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជារួមនៅតែរក្សាភាពល្អប្រសើរដោយមានកំណើនជាប់ជាប្រចាំ ។ តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក បានឡើងថ្លៃ ១% ក្នុងឆ្នាំ២០០៧ ។ គំរិតអតិផរណានៃថ្លៃទំនិញប្រើប្រាស់នៅដើមឆ្នាំមានស្ថានភាពល្អប្រសើរ គួបផ្សំនឹងនយោបាយរូបិយវត្ថុនិងសារពើពន្ធសមស្របផង បានធ្វើឱ្យអត្រាប្តូរប្រាក់ និងអតិផរណាមានភាពល្អប្រសើរ ។ អតិផរណា ឆ្នាំលើឆ្នាំប្រមាណ ៥,៨% ប៉ុណ្ណោះ នៅដំណាច់ឆ្នាំ២០០៧ ។

កត្តាទាំងនេះ បានឆ្លុះបញ្ចាំងពីស្ថិរភាពខាងផ្នែករូបិយវត្ថុ និងការកើនឡើងនៃជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល និងប្រព័ន្ធធនាគារទាំងមូល ។ ការគ្រប់គ្រងទុនបំរុងអន្តរជាតិ យើងបានអនុវត្តដោយផ្អែកលើមូលដ្ឋានប្រុងប្រយ័ត្ន និងសុវត្ថិភាព ។ គិតត្រឹមឆ្នាំ ២០០៧ ទុនបំរុងអន្តរជាតិរបស់យើងបានកើនឡើងដល់ ១.៦០០ លានដុល្លារអាមេរិក ហើយដែលអាចធានាបាននូវការនាំចូលចំនួន ៣ ខែ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តយ៉ាងសកម្មនូវកម្មវិធីកំណែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ ហើយទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ ដូចខាងក្រោម :

*២).* **ការពង្រឹងនិងអភិវឌ្ឍន៍ប្រព័ន្ធធនាគារ** ឱ្យមានការរីកចំរើនទាំងវិសាលភាព និងទំហំសកម្មភាព ។ ប្រព័ន្ធធនាគារត្រូវគេចាត់ទុកថា បានដើរតួនាទីជាស្នូលក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយឱ្យវិនិយោគិនអាចប្រមូលទុនក្នុងស្រុកបន្ថែមតាមរយៈអន្តរការិយកម្មធនាគារចំនួនប្រហែល ៧០០ លានដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០០៦ ចំនួន ៥០០ លានដុល្លារ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ខាងផ្នែកវិសាលភាពក្នុងឆ្នាំ២០០៧ មានធនាគារពាណិជ្ជបើកថ្មីចំនួន ៣ និងធនាគារឯកទេសចំនួន ២ ទៀត បានចូលមកវិនិយោគក្នុងទីផ្សារកម្ពុជា *ជាពិសេស* ការចូលមកវិនិយោគរបស់វិនិយោគិនជនជាតិកូរ៉េ ។ *សរុបមក* ប្រព័ន្ធធនាគារនៅកម្ពុជា មានធនាគារជាតិនៃកម្ពុជា ជាអាជ្ញាធរអាណាព្យាបាល ធនាគារពាណិជ្ជចំនួន ១៨ ធនាគារឯកទេសចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ចំនួន ១៦ អង្គការក្រៅរដ្ឋាភិបាលចុះបញ្ជីចំនួន ៦០ ។ ចំណែកឯ ទំហំសកម្មភាពវិញ យើងឃើញថាប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារកើនបាន ៧៤% ធៀប នឹងឆ្នាំ២០០៦ ដែលកើនចំនួន៤៥% និងឥណទានចំពោះវិស័យឯកជនកើន ៨០% ធៀបនឹងឆ្នាំ២០០៦ ដែលកើនចំនួន ៥១% ។ ការវិវត្តជាវិជ្ជមាននេះ គួបផ្សំជាមួយនឹងការអនុវត្តវិធានការប្រុងប្រយ័ត្ន បានធ្វើឱ្យឥណទានមិន ដំណើរការ (NPL) ថយចុះមកត្រឹម ៥,០១% ធៀបនឹងឆ្នាំ២០០៦ ដែលមានក៏រិតតែ ៥,៣៨% ។

*៣.* **វិស័យមីក្រូហិរញ្ញវត្ថុ :** ត្រូវបានមជ្ឈដ្ឋានក្នុង និងក្រៅប្រទេសទទួលស្គាល់ថា ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ បច្ចុប្បន្ន វិស័យនេះមានភាពរឹងមាំទាំងរចនាសម្ព័ន្ធ និងទាំងទំហំប្រតិបត្តិការរបស់ខ្លួន ដល់ជនបទ *ជាពិសេស* បន្ទាប់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសយកឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុរួចមក ។ ប្រជាជននៅតាមជនបទបានយល់ដឹងពីផលប្រយោជន៍នៃការប្រើប្រាស់ឥណទាន និងការទទួលបានឥណទានយកទៅប្រើប្រាស់ដើម្បីកែប្រែជីវភាពរបស់ខ្លួន ឱ្យកាន់តែប្រសើរឡើង ។ នៅឆ្នាំ២០០៧ មានអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនជាង ៦៧៦ ពាន់គ្រួសារ បានទទួលឥណទានចំនួន ៦៩៥ ពាន់លានរៀល កើនឡើងចំនួន ៨៦% បើប្រៀបធៀបនឹងឆ្នាំ២០០៦ ។ ភាពជឿនលឿននេះ បញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាមានការជឿទុកចិត្ត និងយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទាន កាន់តែប្រសើរឡើង ។

*៤.* **ការងារត្រួតពិនិត្យធនាគារ :** ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារទាំងមូល បានពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារ និងបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យជាប់ជាប្រចាំ តាមរយៈការដាក់កម្មវិធីចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ ។ យើងបានជំរុញឱ្យបណ្តាធនាគារពាណិជ្ជពង្រឹងការគ្រប់គ្រង និងការងារសវនកម្មផ្ទៃក្នុងរបស់ខ្លួន និងបានឱ្យធនាគារទាំងនោះ ធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាសាធារណៈ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន មកលើប្រព័ន្ធធនាគារ ។

យើងបានបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រយោជន៍ដើម្បីកាត់បន្ថយហានិភ័យឥណទាន ជំរុញការផ្តល់ប្រាក់កម្ចីដល់វិស័យឯកជន និងទទួលបានព័ត៌មានឥណទានជាអវិជ្ជមានពិតប្រាកដ ។ យើងក៏បានអនុវត្តនូវកម្មវិធីកុំព្យូទ័រកូប្រា (COBRA) ក្នុងគោលបំណងដើម្បីឱ្យការត្រួតពិនិត្យលើឯកសារកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពសំរាប់ការវិភាគ និងវាយតម្លៃស្ថានភាពធនាគារឱ្យកាន់តែសុក្រឹតឡើង ។

ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយ "*របាយការណ៍ត្រួតពិនិត្យធនាគារពាណិជ្ជប្រចាំឆ្នាំ២០០៦*" ប្រយោជន៍ដើម្បីឱ្យអ្នកដាក់ប្រាក់បញ្ញើ សាធារណជន និងអ្នកសិក្សាស្រាវជ្រាវ បានស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីប្រព័ន្ធធនាគារនៅកម្ពុជា និងអាចស្វែងយល់ពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជាជាអាជ្ញាធរត្រួតពិនិត្យ ។

*៥.ការពង្រឹងក្របខ័ណ្ឌច្បាប់* ៖ នៅឆ្នាំ២០០៧ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយបានផ្តល់សិទ្ធិឱ្យធនាគារជាតិនៃកម្ពុជាបង្កើត និងដឹកនាំអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) ដើម្បីអនុវត្តច្បាប់នេះ ។ ច្បាប់នេះ គឺជាយន្តការបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី *ជាពិសេស* ជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) ក្នុងការប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលពិភពលោកកំពុងយកចិត្តទុកដាក់ ។ ច្បាប់នេះ ក៏ជាមូលដ្ឋានគតិយុត្តិសំខាន់មួយសំរាប់គ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបនូវរាល់ប្រតិបត្តិការ ឬបទល្មើស ដែលទាក់ទងនឹងប្រតិបត្តិការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា និងជាវិធានច្បាប់មួយយ៉ាងសំខាន់សំរាប់លើកមុខមាត់ប្រទេសកម្ពុជាក្នុងឆាកអន្តរជាតិ *ជាពិសេស* ធ្វើឱ្យប្រទេសកម្ពុជាយើង អាចការពារបាននូវហានិភ័យនៃការនិយាយបំផ្លើសថាកម្ពុជា ជាប្រទេសសំរាប់សំអាតប្រាក់ និងហិរញ្ញប្បទានភេរវករ ។

សេចក្តីព្រាងច្បាប់ស្តីពីភតិសន្យា យើងបានបញ្ជូនទៅទីស្តីការគណរដ្ឋមន្ត្រីរួចហើយ ។ ច្បាប់នេះគឺជាមូលដ្ឋានគតិយុត្តមួយសំរាប់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា និងសំរាប់កៀងគរប្រភពទុនរយៈពេលវែងទៅពង្រីកគំរោងវិនិយោគប្រកបដោយចីរភាព ។ ចំពោះការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុវិញ យើងបានបន្តកែលំអវិធានការប្រុងប្រយ័ត្ននិងបទប្បញ្ញត្តិមួយចំនួន ដើម្បីពង្រឹងប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូន មានសុវត្ថិភាព និងមានប្រសិទ្ធភាព ។

*៦.ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥* ៖ ដោយមានកិច្ចសហប្រតិបត្តិការ និងកិច្ចគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) យើងបានធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ឱ្យទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥** ដើម្បីរំកិលទៅអនុវត្តអ្វីដែលនៅសេសសល់ នៅក្នុងដំណាក់ថ្មីខាងមុខទៀត ។ ឯកសារនេះ ត្រូវបានរាជរដ្ឋាភិបាលអនុម័តធ្វើជាផែនទីវិថីសំរាប់ចង្អុលទិស និងកំណត់ដំណាក់កាលអភិវឌ្ឍន៍វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានប្រសិទ្ធភាព ។ យុទ្ធសាស្ត្រនេះក៏ត្រូវបានទទួលស្គាល់ នៅក្នុងក្របខ័ណ្ឌជាតិ ហើយបានចែងក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០០៦-២០១០ របស់រាជរដ្ឋាភិបាល បន្ថែមលើយុទ្ធសាស្ត្រចតុកោណ ប្រយោជន៍ដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍន៍ ប្រកបដោយចីរភាព ។

ការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំ ស្របតាមយន្តការទីផ្សារសេរី គឺត្រូវរៀបចំឱ្យមានប្រព័ន្ធហិរញ្ញវត្ថុមួយមានសុវត្ថិភាព មានការប្រកួតប្រជែងដោយស្មើភាព និងប្រសិទ្ធភាព ក្នុងការកេណ្ឌប្រមូលធនធាន និងបែងចែកធនធាននោះសំរាប់ការវិនិយោគប្រកបដោយចីរភាព និងផលិតភាព ។ លក្ខណៈពិសេសនៃការអនុវត្តឯកសារយុទ្ធសាស្ត្រនេះ គឺមានភាពទន់ភ្លន់ ដោយរាជរដ្ឋាភិបាលអាចកែតម្រូវលើគោលនយោបាយមួយចំនួនដែលចាំបាច់ ដើម្បីឆ្លុះបញ្ចាំងពីការរីកចំរើន និងការប្រែប្រួលនៃល័ក្ខខ័ណ្ឌ និងដើម្បីធ្វើឱ្យមានភាពកាន់តែប្រាកដប្រជា ។

*៧*.**ការងារសវនកម្មផ្ទៃក្នុង** : ក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារត្រួតពិនិត្យផ្ទៃក្នុងតាមរយៈការពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ យើងបានរៀបចំនូវលិខិតបទដ្ឋានចាំបាច់នានា *ដូចជា* ប្រកាសស្តីពីគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ប្រកាសស្តីពីលក្ខន្តិកៈនៃគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ជាដើម ។ នៅឆ្នាំ២០០៧ អាគ្គាធិការដ្ឋានបានចុះធ្វើសវនកម្មនៅនាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយ និងនាយកដ្ឋានគណនេយ្យ សាខាធនាគារជាតិនៃកម្ពុជាខេត្តសៀមរាប បាត់ដំបង ក្រុងព្រះសីហនុ ស្ទឹងត្រែង និងកំពត ហើយនៅឆ្នាំនេះយើងនឹងបន្តធ្វើសវនកម្មនៅតាមនាយកដ្ឋាន និងសាខាខេត្ត-ក្រុងមួយចំនួនទៀត ។

*៨*.**ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង** : ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងប្រតិបត្តិការរបស់ខ្លួនទាំងនៅទីស្នាក់ការកណ្តាល និងសាខាខេត្ត-ក្រុង ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល *ដូចជា* ការទទួលការបង់ពន្ធគ្រប់ប្រភេទ ការគ្រប់គ្រងគណនីរបស់ស្ថាប័នរដ្ឋ និងបានចាត់ចែងសំរួលសារាចរណ៍សាច់ប្រាក់តាមរយៈការបង្វែរសាច់ប្រាក់របស់រតនាគារជាតិ និងបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាដើម ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

*៩*.**ចំពោះកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិវិញ** : នៅឆ្នាំ២០០៧ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានវាយតម្លៃថា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានស្ថិរភាពល្អលើសពីការព្យាករណ៍ទុក ហើយការធ្វើកំណែទំរង់បច្ចុប្បន្នរបស់កម្ពុជា កំពុងស្ថិតនៅលើគន្លងមួយដ៏ត្រឹមត្រូវ ។ IMF បានសន្យាថា នឹងផ្តល់ជំនួយបច្ចេកទេសបន្ថែមទៀតដល់ប្រទេសកម្ពុជា ។

ជាមួយមជ្ឈមណ្ឌល SEACEN ធនាគារជាតិនៃកម្ពុជាបានសហការរៀបចំសិក្ខាសាលានៅខេត្តសៀមរាប និងបញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលានៅបរទេស ដើម្បីផ្លាស់ប្តូរបទពិសោធន៍នៃការគ្រប់គ្រងនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារកណ្តាល ។ យើងបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល SEACEN នៅប្រទេសថៃ ។ ជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) ក្នុងនាមជាសមាជិក ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីចំបង ក្នុងការទំនាក់ទំនង និងទទួលក្រុមបេសកកម្មវាយតម្លៃអញ្ញមញ្ញដែលដឹកនាំដោយធនាគារពិភពលោក មកបំពេញបេសកកម្មនៅកម្ពុជា ដើម្បីវាយតម្លៃពីមូលដ្ឋានច្បាប់របស់ប្រទេសកម្ពុជាក្នុងការអនុវត្តអនុសាសន៍ទាំង ៤០ ស្តីពីការប្រឆាំងការសំអាតប្រាក់ និងអនុសាសន៍ពិសេស ៩ ស្តីពីការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ។ ជាមួយ APRACA ធនាគារជាតិនៃកម្ពុជា បានពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការបណ្តុះបណ្តាល ដោយបានរៀបចំសិក្ខាសាលាថ្នាក់តំបន់មួយនៅខេត្តកំពង់ចាម ដើម្បីផ្លាស់ប្តូរបច្ចេកទេសក្នុងការត្រួតពិនិត្យស្ថាប័នមីក្រូហិរញ្ញវត្ថុ និងការផ្តល់ឥណទានចំពោះវិស័យកសិកម្មនៅជនបទ ។

ចំពោះទំនាក់ទំនងទ្វេភាគីវិញ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ ធនាគារកណ្តាលលុចហ្សំបួរ ធនាគារកណ្តាលប៊ែលហ្ស៊ិក ធនាគារកណ្តាលអាឡឺម៉ង់ និងបានចុះអនុស្សរណៈយោគយល់គ្នាជាមួយធនាគារកណ្តាលកូរ៉េ និងវៀតណាម ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុង ការគ្រប់គ្រងធនាគារកណ្តាល ការបណ្តុះបណ្តាល និងផ្លាស់ប្តូរមន្ត្រីជំនាញនៃធនាគារកណ្តាលជាមិត្តទាំងនោះ ។

**លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងនេះ គឺជាលទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែង កើតចេញពីការចូលរួមនៃកម្លាំងសរុបរបស់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលំអិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់មន្ត្រីរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៀត ។ ក្នុងអង្គសន្និបាតរបស់យើងរយៈពេលពីរថ្ងៃនេះ សូម លោក លោកស្រីទាំងអស់ ខិតខំត្រងត្រាប់ស្តាប់មន្ត្រីឧទ្ទេសនាមរបស់យើងនឹងផ្សព្វផ្សាយអំពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងលើកទិសដៅការងារឆ្នាំ២០០៨ សំរាប់អនុវត្តឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម និងលោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនេះ សូមឱ្យអង្គសន្និបាតរបស់យើងថ្ងៃនេះដំណើរការប្រកបដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**